**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា

## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបិទ
## សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២០

**ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០**

**នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្ទប់ប្រជុំ “ខ”**

**និងតាមវីដេអូខនហ្វើរេន កម្មវិធី BlueJeans**

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!*

ឆ្លងកាត់ការបង្ហាញពីវឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផល ជាពិសេសមេរៀនជាបទពិសោធន៍ល្អៗដែលបានមកពីការអនុវត្តរបស់សមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅទូទាំងប្រទេស នៅក្នុងអង្គសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នាព្រឹកនេះ តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការអបអរសាទរ និងកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះសមាជិក សមាជិកានៃអង្គសន្និបាត និងនៅទូទាំងប្រទេស ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មចូលរួមប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យទទួលបាននូវជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

កត្តាជោគជ័យទាំងអស់នេះ គឺពិតជាបានមកពីការរួមចំណែករបស់សមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដែលជាក្រសួង ស្ថាប័ន រាជធានី ខេត្ត របស់រាជរដ្ឋាភិបាលកម្ពុជា

ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ បណ្តាញក្រុមប្រឈមខ្ពស់នឹងការចម្លងមេរោគអេដស៍ៗលៗ រួមជាមួយនឹងការប្តេជ្ញាចិត្តដ៏ត្រឹមត្រូវ និងមោះមុតផ្នែកនយោបាយពីថ្នាក់ដឹកនាំកំពូលរបស់រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ "**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**" និងការគាំទ្រដោយមិនចេះនឿយហត់ផ្នែកសង្គមពី "**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**" ប្រធានកាកបាទក្រហមកម្ពុជា។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

ក្នុងនាមជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្លងតាមការពិភាក្សាយ៉ាងផុសផុលនៅក្នុងអង្គសន្និបាតនាពេលនេះ ខ្ញុំសូមចូលរួមចំណែកផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

**១.** បន្តការអនុវត្តរួមគ្នានូវគម្រោងផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៥ (២០១៩-២០២៣)។

**២.** ធានាឱ្យបាននូវចីរភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយបង្កើត និងធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិសេស ក្នុង ឃុំ សង្កាត់ ទាំងអស់នៅទូទាំងប្រទេស និងធ្វើការបញ្រ្ជាប និងបញ្ចូលសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងផែនការរួមរបស់ក្រសួង ស្ថាប័ន ខេត្ត រាជធានី ស្រុក ខណ្ឌ និងឃុំ សង្កាត់។

**៣.** ធ្វើសមាហរណកម្ម កម្មវិធីបង្ការ ថែទាំ និងព្យាបាលអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាល ដើម្បីទទួលបាននូវការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងចីរភាព។

**៤.** ចូលរួមពង្រឹងយន្តការថ្នាក់ក្រោមជាតិឱ្យម្ចាស់ការគាំទ្រដល់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដោយធ្វើការអង្កេត តាមដានការអនុវត្តសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងផែនការឃុំ សង្កាត់។

**៥.** រក្សាស្រោមអនាម័យឱ្យមាននៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដែលត្រូវការប្រើប្រាស់ប្រកបដោយគុណភាពខ្ពស់ និងបន្តលើកទឹកចិត្តដល់ក្រុមយុវវ័យដែលរួមភេទដូចគ្នា ឱ្យទៅពិនិត្យឈាមរកមេរោគអេដស៍ និងប្រើប្រាស់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ តាមរយៈការប្រើស្រោមអនាម័យ១០០% នៅពេលរួមភេទ។

**៦.** បន្តបង្កើនលទ្ធភាពទទួលបាននូវយន្តការគាំពារសង្គមនិងសេវាសង្គមសម្រាប់អ្នកផ្ទុកមេរោគ អេដស៍ និងអ្នកជំងឺអេដស៍ ។

**៧.** សូមអំពាវនាវដល់អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ បន្តចូលរួមជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ថែមទៀតតាមគ្រប់រូបភាព ជាកម្លាំងកាយ ប្រាជ្ញាស្មារតី សម្ភារ និងថវិកាដើម្បីពង្រីកអន្តរាគមន៍

ប្រយុទ្ធនឹងជំងឺអេដស៍ឱ្យឈានទៅសម្រេចបាននូវអត្រាគ្របដណ្ដប់ លើភូមិសាស្រ្ត និងក្រុមគោលដៅឱ្យបាន១០០%។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

ខ្ញុំមានសង្ឃឹមថា អនុសាសន៍ទាំង៧ចំណុចខាងលើនេះ នឹងអាចយកទៅប្រើប្រាស់ជាចលករក្នុងការអនុវត្តគម្រោងផែនការសកម្មភាពជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងឆ្នាំខាងមុខឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរសព្ទសាធុការជូនអង្គសន្និបាតទាំងមូល សូមឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ទទួលបាននូវសុខភាពល្អ និងសម្រេចបាននូវជោគជ័យថ្មីៗបន្ថែមទៀត នាឆ្នាំ២០២១ខាងមុខនេះ និងសូមប្រកាសបិទ "**សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២០**" ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***